# ការអនុវត្តន៍ល្អ
## ផ្ទាំងរូបភាពអប់រំ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ផ្ទាំងរូបភាពអប់រំ គឺជាវិធីដែលមានប្រសិទ្ធិភាពដើម្បីអប់រំកម្មករ ។ វិធីនេះមានប្រសិទ្ធិភាពណាស់ ព្រោះរូបភាពគឺជាទំរង់ផ្សព្វផ្សាយដែលមានឥទ្ធិពលអាចផ្តោតចំទៅលើឥរិយាបថអ្វីមួយបាន ។ ឧទាហរណ៏ ផ្ទាំងរូបភាពអប់រំដែលមានប្រយោជន៏សំរាប់រោងចក្រកាត់ដេរដទៃទៀតរួមមាន ផ្ទាំងរូបភាពអប់រំស្តីពីកាយវិការលើកដាក់ ការពាក់ម៉ាសការពារ និងសុខភាពបន្តពូជ ។

### ការអនុវត្តន៏ល្អផ្ទាំងរូបភាពអប់រំ

ប្រើផ្ទាំងរូបភាពអប់រំដើម្បីដោះស្រាយបញ្ហា និងកង្វល់នានា ។ ឧទាហរណ៏ ប្រសិនបើកម្មករកំពុងមានបញ្ហាខ្នង ផ្ទាំងរូបភាពអប់រំដែលបង្ហាញពីកាយវិការលើកដាក់យ៉ាងត្រឹមត្រូវ ប្រហែលជាអាចមានសារៈប្រយោជន៏ (រូបភាពទី១ និងទី២) ។

បញ្ចូលខ្លឹមសារតែមួយបានហើយ ក្នុងផ្ទាំងរូបភាពអប់រំមួយ ។ កុំព្យាយាមផ្សព្វផ្សាយគោលបំណងច្រើនក្នុងផ្ទាំងរូបភាពអប់រំមួយ ព្រោះវានឹងធ្វើអោយខ្លឹមសារកាន់តែពិបាកយល់ ។

ប្រើប្រាស់ផ្ទាំងរូបភាពអប់រំដើម្បី (១) ផ្លាស់ប្តូរ (ឬពង្រឹង) ឥរិយាបថ ឬ (២) បង្កើនចំណេះដឹង ។

ដាក់បង្ហាញផ្ទាំងរូបភាពអប់រំនៅកន្លែងដែលមានប្រយោជន៏ និងងាយស្រួលមើលឃើញ ។

ផ្ទាំងរូបភាពអប់រំ គឺជាវិធីល្អមួយសំរាប់ធ្វើការផ្សព្វផ្សាយ ប៉ុន្តែវាកាន់តែមានប្រយោជន៏ថែមទៀតនៅពេលគេប្រើប្រាស់ដើម្បីបន្ថែមពតិមានដល់កម្មវិធីបណ្តុះបណ្តាលណាមួយ ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៏:

- ✓ បង្ហាញទស្សនៈវិជ្ជមាននៅកន្លែងធ្វើការ
- ✓ បង្ហាញកម្មករ និងអ្នកទិញថា ក្រុមហ៊ុនយកចិត្តទុកដាក់នឹងសុខមាលភាពបុគ្គលិករបស់ខ្លួន

### តាមរបៀបណា:

- ✓ បង្កើតផ្ទាំងរូបភាពអប់រំដោយខ្លួនឯង គូររូប ឬថតរូបកម្មករហើយបន្ថែមអត្ថបទ
- ✓ សាកសួរអង្គការ ILO ឬអង្គការនានាដទៃទៀត ប្រសិនបើគេមានរូបនានាដែលមានប្រយោជន៏
- ✓ យកផ្ទាំងរូបភាព ឬរូបភាពដោយមិនគិតថ្លៃចេញពីអ៊ីនធឺណិត ហើយបន្ថែមអត្ថបទជាភាសាខ្មែរ ឬចិន

### តំលៃ:

**$**

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់